# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ២
បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# ការចេញដីកាសម្រេចរក្សាការពារ

រៀបចំដោយៈ

-លោក **ឈឿន គុយអេង** សមាជិកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-កញ្ញា **គន្ធា ស្រីសុជាតា** សមាជិកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ក្នុងគោលបំណងទទួលបានការដោះស្រាយដោយផ្អែកតាមច្បាប់ និងការការពារសិទ្ធិបុគ្គលឯកជន[1]។ ប៉ុន្តែ បើត្រូវរង់ចាំរហូតដល់តុលាការចេញសេចក្តីសម្រេចដែលកំណត់ជាស្ថាពរអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនៅក្នុងបណ្តឹងអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណី ប្រសិនបើមានការប្រែប្រួលចំពោះស្ថានភាពនៃទ្រព្យសម្បត្តិរបស់ភាគី ឬស្ថានភាពផ្សេងៗទៀត នោះនឹងអាចជាហេតុនាំឱ្យកើតមានឧបសគ្គក្នុងការអនុវត្តសេចក្តីសម្រេចតុលាការនាពេលអនាគតផងដែរ។ ដើម្បីបង្ការស្ថានភាពនេះ, ក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតឱ្យមាននូវយន្តការស្តីពីការចាត់ចែងរក្សាការពារ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល ក្នុងគោលគំនិតថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ[2]។ ការចាត់ចែងរក្សាការពារ គឺជាការធានាជាបណ្តោះអាសន្ន ដែលពុំជះឥទ្ធិពលដល់ការសម្រេចលើបណ្តឹងអង្គសេចក្តីឡើយ។ នៅមុនពេលមានក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ យន្តការនេះត្រូវបានប្រើប្រាស់ក្រោមទម្រង់ជា "ការសម្រេចជាវិធានការណ៍ប្រញាប់ និងបណ្តោះអាសន្ន"[3]។ ក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតឱ្យមាននូវយន្តការចាត់ចែងរក្សាការពារនេះ ដែលមានចរិតលក្ខណៈបន្ទាប់បន្សំពីបណ្តឹងអង្គសេចក្តី, មានលក្ខណៈបណ្តោះអាសន្ន និងមានលក្ខណៈបន្ទាន់បង្ខំ និងលក្ខណៈសម្ងាត់ ហើយការសម្រេចរបស់តុលាការត្រូវធ្វើឡើងដោយ ឆាប់រហ័សជាងបណ្តឹងអង្គសេចក្តី និងមិនឆ្លងកាត់នីតិវិធីស្មុគស្មាញឡើយ។

ផ្អែកតាមមាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ការចាត់ចែងរក្សាការពារ មាន ២ ប្រភេទរួមមានៈ (១)-ការរឹបអូសជាបណ្តោះអាសន្ន និង (២)-ការចាត់ចែងជាបណ្តោះអាសន្ន ដែលមានការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។ ***ការរឹបអូសជាបណ្តោះអាសន្ន*** សំដៅដល់ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ

---

1. មាត្រា ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

2. មាត្រា ៥៣០ នៃក្រមនីវិតិធីរដ្ឋប្បវេណី

3. សេចក្តីណែនាំលេខ ០៩/០៤ តកនសត ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤ របស់តុលាការកំពូល ស្តីពីការសំរេចជាវិធានការណ៍ប្រញាប់ និងបណ្តោះអាសន្ន។

ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ ការរឹបអូសជាបណ្តោះអាសន្ន មានគោលបំណងថែរក្សាតម្លៃនៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬរបស់បុគ្គលពាក់ព័ន្ធ ដែលអាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំសម្រាប់ទូទាត់សងនូវសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល តាមរយៈការចាត់ចែងប្តូរទ្រព្យសម្បត្តិនេះជាប្រាក់ សម្រាប់សងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៅពេលម្ចាស់បំណុលទទួលបានសាលក្រម ឬសាលដីកាស្ថាពរនាពេលអនាគត។ ការរឹបអូសជាបណ្តោះអាសន្ននេះ ត្រូវធ្វើឡើងតាមរយៈការចេញជា **“ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន”**។ ដោយឡែក, ***ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ*** សំដៅដល់ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទនេះ ជាការចាត់ចែងដើម្បីរក្សាឱ្យបាននូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ កុំឱ្យមានការប្រែប្រួល (ជាអាទិ៍ មិនឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករ ឬមានការចុះបន្ទុកលើវត្ថុដែលជាកម្មវត្ថុនៃវិវាទ) ដោយមិនកម្រិតត្រឹមតែការថែរក្សាតម្លៃនៃវត្ថុដូចករណីនៃការរឹបអូសជាបណ្តោះអាសន្នឡើយ។ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ អាចមាន ២ ប្រភេទ គឺ ***ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់*** ដូចមានចែងក្នុងមាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង ***ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង***។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាប់ គឺជាការសម្រេចដែលបង្គាប់ឱ្យដកហូតការកាន់កាប់ពីកូនបំណុល ហើយបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះជំនួសវិញ។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាការសម្រេចហាមឃាត់មិនឱ្យចាត់ចែងវត្ថុ ដែលអាចជាការហាមឃាត់ការលក់ ដូរ ជួល ឬដាក់ប្រាតិភោគជាដើម។រីឯ ***ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន*** សំដៅដល់ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។ ខុសពីការរឹបអូសជាបណ្តោះអាសន្នដែលមានគោលបំណងថែរក្សាតម្លៃនៃទ្រព្យសម្បត្តិ និងខុសពីការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទដែលមានគោលបំណងរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុ, ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ននេះ មាន

គោលបំណងកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ដែលស្ថានភាពជាបណ្ដោះអាសន្ននេះ អាចមានជាអាទិ៍ សិទ្ធិទាក់ទងនឹងឋានៈបុគ្គល ឬសិទ្ធិក្នុងទំនាក់ទំនងញាតិ។ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងក្រោមទម្រង់ជា **"ដីកាសម្រេចចាត់ចែងបណ្ដោះអាសន្ន"**។

ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីក្របខ័ណ្ឌគតិយុត្តនៃការចេញដីកាសម្រេចរក្សាការពារទាំង ២ ប្រភេទខាងលើ *(១)* គឺ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។ ច្បាប់បានកំណត់អំពីគោលគំនិតច្បាស់លាស់នៃការចេញដីកាទាំង ២ ប្រភេទនេះ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្ដែង ដោយបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួនមិនមានភាពច្បាស់លាស់ ធ្វើឱ្យការចេញដីកាសម្រេចរក្សាការពារ នៅមិនទាន់មានសង្គតិភាពគ្នាទាំងស្រុងនៅឡើយទេ ហើយការអនុវត្តខ្លះក៏អាចប្រាសចាកពីស្មារតីដើមនៃក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ *(២)*។ តើការចេញដីកាសម្រេចរក្សាការពារទៅតាមប្រភេទនីមួយៗខាងលើ ត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះ? តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការអនុវត្តជាក់ស្ដែងពាក់ព័ន្ធនឹងការចេញដីកាសម្រេចរក្សាការពារនេះ?

## ១- ក្របខ័ណ្ឌគតិយុត្តនៃការចេញដីកាសម្រេចរក្សាការពារ

ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីលក្ខខណ្ឌដែលត្រូវបំពេញ *(ក)* និងនីតិវិធីដែលត្រូវអនុវត្ត *(ខ)* សម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និង ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។

### ក-លក្ខខណ្ឌសម្រាប់ការចេញដីកាសម្រេចរក្សាការពារ

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន អាចធ្វើទៅបាន លុះត្រាតែបានកំណត់ជាមុនអំពី៖ អត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ **(ក-១)**, ភាពចាំបាច់នៃការចេញដីកាសម្រេចរក្សាការពារ **(ក-២)** និង កម្មវត្ថុនៃដីកាសម្រេចរក្សាការពារ **(ក-៣)**។

### ក-១.ការកំណត់អំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

- **ចំពោះការរឹបអូសជាបណ្ដោះអាសន្ន៖** ម្ចាស់បំណុលត្រូវបញ្ជាក់ជាមុនអំពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ខ្លួនចំពោះកូនបំណុល។ សិទ្ធិលើបំណុលដែលជាមូលដ្ឋានសម្រាប់ការស្នើសុំ

ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ ត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណង ឱ្យសងជាប្រាក់ ដែលរួមមានជាអាទិ៍ សិទ្ធិទាមទារឱ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចី បរិភោគ, សិទ្ធិទាមទារឱ្យបង់ថ្លៃលក់ទិញដោយផ្អែកលើកិច្ចសន្យាលក់ទិញ ឬ សិទ្ធិទាមទារឱ្យ បង់ថ្លៃឈ្នួលដោយផ្អែកលើភតិសន្យា ជាដើម។ សិទ្ធិលើបំណុលផ្សេងទៀតដែលមិនមាន គោលបំណងឱ្យសងជាប្រាក់ ជាអាទិ៍ សិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ មិនអាចជាមូលដ្ឋានសម្រាប់ ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះបានទេ។ ការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើ បំណុលនេះ ត្រូវធ្វើឡើងតាមវិធីបញ្ជាក់ដំបូង ដែលជាការដាក់នូវភស្តុតាងជាឯកសារដែល តុលាការអាចធ្វើការត្រួតពិនិត្យបានភ្លាមៗ ដូចជា កិច្ចសន្យាខ្ចីបរិភោគជាលាយលក្ខអក្សរណ៍, លិខិតប្រគល់ទទួលប្រាក់ ឬតារាងប្រតិបត្តិការទូទាត់ប្រាក់ ជាដើម។ ដីកាសម្រេចរឹបអូសជា បណ្តោះអាសន្ន អាចចេញបានទោះបីជាសិទ្ធិលើបំណុលនោះមានភ្ជាប់នឹងលក្ខខណ្ឌ ឬមាន ពេលកំណត់ក៏ដោយ។

- **ចំពោះការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ៖** សិទ្ធិលើ បំណុលដែលអាចជាមូលដ្ឋាននៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ គឺ ជាសិទ្ធិលើបំណុលដែលមានការពាក់ព័ន្ធដោយផ្ទាល់លើវត្ថុជាក់លាក់ ក្រៅពីសិទ្ធិដែលមានគោល បំណងឱ្យសងជាប្រាក់។ កថាខណ្ឌទី១ នៃមាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាក យ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។ សិទ្ធិ ដែលត្រូវបានរក្សាការពារនេះ រួមមានជាអាទិ៍ សិទ្ធិទាមទារឱ្យប្រគល់វត្ថុ, សិទ្ធិទាមទារឱ្យបណ្តេញ ចេញពីដី, សិទ្ធិទាមទារឱ្យរុះរើការរផ្សេងៗ ឬសិទ្ធិទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីអំពីសិទ្ធិដែលមាន លើវត្ថុ។

- **ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន៖** សិទ្ធិ ដែលអាចត្រូវបានរក្សាការពារ ដោយការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះ អាសន្ននេះ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ រួមទាំងសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសង ជាប្រាក់ សិទ្ធិលើបំណុលដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ឬសិទ្ធិដែលទាក់ទងនឹងឋានៈ បុគ្គល ដូចជាទំនាក់ទំនងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងឪពុកម្តាយ និងកូន ជាដើម។

## ក-២. ការកំណត់អំពីភាពចាំបាច់នៃការចេញដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារនេះ អាចចេញបានតែក្នុងករណីដែលមានភាពចាំបាច់ប៉ុណ្ណោះ។ តើភាពចាំបាច់នេះត្រូវកំណត់យ៉ាងដូចម្ដេច?

**- ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន៖** ផ្អែកតាមមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន កើតមានឡើង *"ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ"*។ តើមានករណីណាខ្លះដែលធ្វើឱ្យការអនុវត្តដោយបង្ខំនឹងមិនអាចអនុវត្តបាន ឬនឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ? ការវាយតម្លៃនេះគឺជាឆន្ទានុសិទ្ធរបស់តុលាការ។ ជាក់ស្ដែង ភាពចាំបាច់នេះ អាចកើតមានឡើងក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ទំនងជាអាចធ្លាក់តម្លៃយ៉ាងខ្លាំង ឬធ្លាក់បរិមាណ ឬគុណភាព ដោយសារការចាយវាយខ្ជះខ្ជាយ ការដាក់លក់ក្នុងតម្លៃថោក និងការបង្វែរទ្រព្យដើម្បីគេចវេសពីការរឹបអូស ឬការគេចខ្លួន និងការប្ដូរលំនៅឋានជាញឹកញាប់របស់កូនបំណុលដែលអាចជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំជាដើម។

**- ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ៖** មាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ថា ភាពចាំបាច់នេះ គឺសំដៅដល់ *"ករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុ"*។ ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ កើតឡើងនៅពេលមានហានិភ័យនៃការខូចខាត ឬហានិភ័យនៃការបង្វែរ ការផ្ទេរ ឬការរារាំងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុវិវាទដោយកូនបំណុល ឬតតិយជន ដូចជាករណីកូនបំណុលដែលជាអ្នកលក់បានព្យាយាមលក់ដីបន្តទៅឱ្យអ្នកផ្សេង ខណៈពេលដែលម្ចាស់បំណុលដែលជាអ្នកទិញកំពុងទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ ឬ ករណីដែលកូនបំណុលកំពុងបន្តការសាងសង់ ខណៈពេលដែលម្ចាស់បំណុលកំពុងទាមទារឱ្យរុះរើសំណង់ទាំងឡាយនៅលើដីវិវាទដោយផ្អែកលើការបំពានកម្មសិទ្ធិ ជាអាទិ៍។

**- ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន៖** កថាខណ្ឌទី២ នៃមាត្រា៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បី ជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល

ចំពោះទំនាក់ទំនងគតិយុត្តិដែលមានវិវាទ។ ភាពចាំបាច់នៃការរក្សាការពារប្រភេទនេះ ត្រូវបានវាយតម្លៃដោយ**ផ្អែកលើស្ថានភាពចាំបាច់របស់ម្ចាស់បំណុល មិនមែនផ្អែកលើសកម្មភាពនៃការចាត់ចែងទ្រព្យសម្បត្តិ ឬវត្ថុវិវាទ ដូចករណីការរឹបអូសជាបណ្តោះអាសន្ន ឬការចាត់ចែងបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទឡើយ**។ ជាឧទាហរណ៍ ចំពោះករណីវិវាទពាក់ព័ន្ធនឹងភាពស្របច្បាប់នៃការបញ្ឈប់ពីការងារ ហើយកម្មករនិយោជិតនឹងជួបការលំបាកសម្រាប់ជីវភាពប្រចាំថ្ងៃ ក្នុងអំឡុងពេលដំណើរការក្តីជាមួយភាគីនិយោជក ប្រសិនបើកម្មករនិយោជិតបាត់បង់ប្រាក់ខែក្នុងអំឡុងពេលដំណើការក្តី, ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន អាចសម្រេចឱ្យនិយោជកបន្តបង់ប្រាក់ខែឱ្យទៅកម្មករនិយោជិតជាបណ្តោះអាសន្នសិន រហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរដែលកំណត់ជាក់លាក់អំពីភាពស្របច្បាប់នៃការបញ្ឈប់ពីការងារ។ ដូចគ្នាផងដែរ ចំពោះករណីជនរងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍ ដែលត្រូវការថវិកាជាបន្ទាន់សម្រាប់ព្យាបាលរបួស។ ចំពោះករណីនេះ ដោយជនរងគ្រោះកំពុងស្ថិតនៅក្នុងស្ថានភាពបន្ទាន់ដែលមិនអាចរង់ចាំរហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរ, ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន អាចសម្រេចឱ្យកូនបំណុលដែលអាចជាជនបង្ក ឬក្រុមហ៊ុនធានារ៉ាប់រង បង់ប្រាក់សំណងមួយផ្នែក ឬទាំងស្រុងឱ្យទៅម្ចាស់បំណុលជាមុនសិន រហូតដល់ពេលមានសាលក្រម ឬសាលដីកាស្ថាពរដែលកំណត់អំពីចំនួនទឹកប្រាក់សំណងជាក់លាក់។

### ក-៣. ការកំណត់នូវកម្មវត្ថុនៃដីកាសម្រេចរក្សាការពារ

- **ការរឹបអូសជាបណ្តោះអាសន្ន៖** ជាគោលការណ៍ ក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន, តុលាការត្រូវកំណត់ឱ្យជាក់លាក់នូវកម្មវត្ថុនៃការរឹបអូស[4]។ ដោយឡែកចំពោះការរឹបអូសវត្ថុដែលជាចលនវត្ថុ តុលាការអាចចេញដីកាសម្រេចនេះបានដោយមិនចាំបាច់កំណត់កម្មវត្ថុនោះទេ។ ការរឹបអូសជាបណ្តោះអាសន្ននេះ អាចធ្វើបានចំពោះចលនវត្ថុ[5], អចលនវត្ថុ[6], សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[7] និងនាវា[8]។

---

[4]. មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5]. មាត្រា ៥៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[6]. មាត្រា ៥៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[7]. មាត្រា ៥៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[8]. មាត្រា ៥៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- **ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ៖** ការចាត់ចែងនេះធ្វើឡើងដើម្បីរក្សាទុកឱ្យបាននូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ ហេតុដូចនេះ ការចាត់ចែងជាបណ្ដោះអាសន្ននេះ ត្រូវធ្វើចំពោះតែវត្ថុជាក់លាក់ដែលជាកម្មវត្ថុនៃវិវាទតែប៉ុណ្ណោះ។

- **ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន៖** គោលបំណងនៃការចាត់ចែងរក្សាការពារប្រភេទនេះ មិនមែនជាការថែរក្សាទ្រព្យសម្បត្តិរបស់កូនបំណុលសម្រាប់អនុវត្តដោយបង្ខំក្នុងពេលអនាគតដូចករណីការរឹបអូសជាបណ្ដោះអាសន្នឡើយ តែជាការទប់ស្កាត់ ឬការដកចេញនូវគ្រោះថ្នាក់ ឬការខូចខាតពិសេសដែលអាចកើតឡើងចំពោះម្ចាស់បំណុល ក្នុងអំឡុងពេលដែលទំនាក់ទំនងគតិយុត្តមិនទាន់អាចត្រូវបានកំណត់ជាក់លាក់ដោយសាលក្រម ឬសាលដីកាស្ថាពរ។

### ខ- នីតិវិធីសម្រាប់ការចេញដីកាសម្រេចរក្សាការពារ

- **សមត្ថកិច្ចតុលាការ៖** ជាគោលការណ៍, ការរក្សាការពារអាចធ្វើឡើងនៅមុនពេលមានបណ្ដឹងអង្គសេចក្ដី ឬនៅក្នុងអំឡុងពេលបណ្ដឹងអង្គសេចក្ដីបាន។ រឿងក្ដីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី សំដៅទៅលើតុលាការនៃការជំនុំជម្រះលើកទី១ ក្នុងករណីដែលបណ្ដឹងអង្គសេចក្ដីកំពុងស្ថិតនៅក្នុងចំណាត់ការរបស់សាលាដំបូង ឬតុលាការកំពូល។ ប៉ុន្តែ បើសិនជាបណ្ដឹងអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍[៩]។ ចំពោះករណីមុនពេលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការមានសមត្ថកិច្ច គឺតុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីនៃបណ្ដឹងអង្គសេចក្ដីដែលនឹងធ្វើនាពេលអនាគត ហើយម្ចាស់បំណុលអាចជ្រើសរើសយកតុលាការណាមួយបាន ប្រសិនបើតុលាការមានសមត្ថកិច្ចមានច្រើន។ ដោយឡែក, ចំពោះការរឹបអូសជាបណ្ដោះអាសន្នដែលមានកម្មវត្ថុជាសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សាលាដំបូងដែលមានសមត្ថកិច្ចជម្រះក្ដីនៅលំនៅឋានរបស់កូនបំណុលទី៣ គឺជាតុលាការដែលមានសមត្ថកិច្ច។ សមត្ថកិច្ចរបស់តុលាការចំពោះសំណុំរឿងរក្សាការពារជាសមត្ថកិច្ចផ្ដាច់មុខ។

---

៩. មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- **ទម្រង់នៃសេចក្តីសម្រេច៖** ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច។ ហេតុដូចនេះ តុលាការអាចចេញដីកាសម្រេចនេះ ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ឬការសួរភាគីបាន[10]។ ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយលក្ខណៈសម្ងាត់ ជាទូទៅតុលាការត្រូវចេញដីកាសម្រេចនេះដោយគ្រាន់តែសួរម្ចាស់បំណុលប៉ុណ្ណោះ[11]។ តុលាការអាចពិនិត្យលើការបំពេញលក្ខខណ្ឌនៃការចេញរក្សាការពារ ដោយផ្អែកលើឯកសារដែលម្ចាស់បំណុលបានដាក់ ដោយមិនចាំបាច់ជូនដំណឹង ឬស្តាប់ការលើកឡើងរបស់កូនបំណុលឡើយ។ ដូចគ្នាផងដែរ តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ដោយមិនបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរភាគីនោះទេ។ ផ្ទុយទៅវិញ, ក្នុងការសម្រេចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈបណ្តោះអាសន្ន, តុលាការត្រូវតែធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬនីតិវិធីសាកសួរដែលកូនបំណុលអាចចូលរួមបានជាដាច់ខាត[12] ដោយសារការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ននេះ មានលក្ខណៈជាការសម្រេចលើខ្លឹមសារនៃសិទ្ធិទាមទារលើអង្គសេចក្តីតែម្តង ដែលបង្កនូវការប៉ះពាល់ដល់សិទ្ធិរបស់កូនបំណុល លើសពីការរក្សាការពារ ២ ផ្សេងទៀត។ ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីក៏អនុញ្ញាតឱ្យតុលាការអាចចេញដីកាសម្រេចនេះភ្លាមៗបានដោយពុំឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬនីតិវិធីសាកសួរបានដែរ បើសិនជាការឆ្លងកាត់នីតិវិធីនេះធ្វើឱ្យគោលបំណងនៃការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននេះ មិនបានសម្រេចទាល់តែសោះចំពោះស្ថានភាពពិសេសមួយចំនួន។ ឧទាហរណ៍ ការរង់ចាំនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ធ្វើឱ្យហួសពេលសម្រាប់ព្យាបាលដល់ម្ចាស់បំណុលដែលរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ជាដើម។

- **ការបង្គាប់ឱ្យដាក់ប្រាតិភោគ និងប្រាក់រំដោះ៖** ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចធ្វើឡើងដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ តាមឆន្ទានុសិទ្ធិរបស់តុលាការ[13]។ ការបង្គាប់ឱ្យដាក់ប្រាតិភោគ គឺដើម្បីធានានូវការផ្តល់សំណងជូនកូនបំណុលវិញ

---

10. មាត្រា ៥៣៩ និង មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

11. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគីស្តីពីការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ទំព័រ ១៩៨។

12. កថាខណ្ឌទី៤ នៃមាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

13. មាត្រា ៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ចំពោះការរឹបអូសជាបណ្ដោះអាសន្នដែលមានលក្ខណៈមិនត្រឹមត្រូវចំពោះកូនបំណុល[14]។ ចំនួននៃប្រាតិភោគត្រូវវាយតម្លៃដោយផ្អែកតាមតម្លៃនៃកម្មវត្ថុដែលត្រូវបានរក្សាការពារ។ លើសពីនេះ, នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់អំពីចំនួននៃប្រាក់រំដោះជាដាច់ខាត ដើម្បីកូនបំណុលអាចទទួលបានការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន[15]។ ប្រាក់រំដោះ គឺជាប្រព័ន្ធដែលបង្កើតឡើងក្នុងគោលបំណងការពារកូនបំណុល ពីការរឹបអូសជាបណ្ដោះអាសន្នដែលមិនមានភាពចាំបាច់។ មានន័យថា បើកូនបំណុលមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្ញើនៅតុលាការដើម្បីធានាការសងបំណុលរួចហើយ នោះការរឹបអូសជាបណ្ដោះអាសន្នលែងមានន័យទៀតហើយ។ ប្រាក់រំដោះត្រូវផ្ញើនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬតុលាការអនុវត្តការរក្សាការពារ[16]។ ដូចគ្នាផងដែរចំពោះការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ, តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ ប៉ុន្តែ តុលាការមិនត្រូវកំណត់អំពីចំនួននៃប្រាក់រំដោះដូចការរឹបអូសជាបណ្ដោះអាសន្នឡើយ ពីព្រោះការរក្សាការពារនេះធ្វើឡើងដោយពាក់ព័ន្ធនឹងវត្ថុជាក់លាក់ មិនមែនពាក់ព័ន្ធតែនឹងតម្លៃនៃវត្ថុសម្រាប់លក់ដោយបង្ខំឡើយ។

- **បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ៖** ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារមាន ៣ ប្រភេទ រួមមាន៖ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ, ការស្នើសុំលុបចោលនូវការរក្សាការពារ និង បណ្ដឹងជំទាស់។ ការតវ៉ាចំពោះរក្សាការពារ និងការស្នើសុំលុបចោលនូវការរក្សាការពារ ត្រូវធ្វើនៅតុលាការដើមដែលចេញដីកាសម្រេចរក្សាការពារ។ រីឯបណ្ដឹងជំទាស់ត្រូវធ្វើទៅតុលាការថ្នាក់លើនៃតុលាការដើម។

**ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ** គឺជាឱកាសដែលផ្ដល់ឱ្យកូនបំណុលដែលពុំអាចចូលរួមនៅក្នុងនីតិវិធីមុន អាចដាក់នូវមធ្យោបាយតទល់ និងការពារខ្លួនបាន និងស្នើសុំឱ្យតុលាការដែលបានចេញដីកាសម្រេចរក្សាការពារធ្វើការវិនិច្ឆ័យអំពីភាពត្រឹមត្រូវនៃដីកាសម្រេចរក្សាការពារឡើងវិញ ពីព្រោះការចេញដីកាសម្រេចនេះអាចមានការពិចារណាមិនបាន

14. "នៅប្រទេសជប៉ុន ស្ទើរតែគ្មានដីកាសម្រេចរក្សាការពារណាដែលមិនបង្គាប់ឱ្យដាក់ប្រាតិភោគនោះទេ"។ សូមអានឯកសារពន្យល់ "ការរក្សាការពារក្នុងរឿងរដ្ឋប្បវេណី ផ្នែកទី២" ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ MAEDA Yuta, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨, ទំព័រទី១៨។

15. មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

16. មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ពេញលេញ ដោយសារតុលាការត្រូវវិនិច្ឆ័យជាលក្ខណៈបន្ទាន់បង្ខំ និងធ្វើការពិនិត្យតែសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលប៉ុណ្ណោះ។ នៅក្នុងការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវពិនិត្យមើលអំពីសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ ដោយត្រូវឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ដើម្បីផ្ដល់ទៅឱ្យភាគី (ជាពិសេសកូនបំណុល) នូវការធានានៅក្នុងការចូលរួមនីតិវិធី[17]។ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារនេះ មាន ៣ប្រភេទ[18] គឺៈ (ទី១)-ការទទួលស្គាល់ (ចំពោះដីកាសម្រេចរក្សាការពារដែលមានលក្ខណៈត្រឹមត្រូវ), (ទី២)-ការផ្លាស់ប្ដូរ (ចំពោះដីកាសម្រេចរក្សាការពារដែលត្រូវកែសម្រួល) និង (ទី៣)-ការលុបចោល (ចំពោះដីកាសម្រេចរក្សាការពារដែលមានលក្ខណៈមិនត្រឹមត្រូវ)។ ចំពោះដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារពុំមានអានុភាពទេ បើមិនទាន់ចូលជាស្ថាពរ ប៉ុន្តែតុលាការអាចប្រកាសថាដីកាសម្រេចលុបចោលនេះមានអានុភាពភ្លាមៗ បើយល់ឃើញថាចាំបាច់ពិសេស[19]។

**បណ្ដឹងជំទាស់ៈ** ផ្អែកតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ អាចប្ដឹងជំទាស់បានក្នុងអំឡុងពេល ២ សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន។ ជាគោលការណ៍, តុលាការនៃបណ្ដឹងជំទាស់ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីតវ៉ាចំពោះដីការក្សាការពារ ពោលគឺការវិនិច្ឆ័យលើសិទ្ធិលើបំណុលដែលត្រូវរក្សាការពារ, ភាពចាំបាច់នៃការរក្សាការពារ និងការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបានជាអាទិ៍។ ការសម្រេចសេចក្ដីរបស់តុលាការនៃបណ្ដឹងជំទាស់ ជាការសម្រេចសេចក្ដីដែលបិទផ្លូវតវ៉ា ដោយភាគីមិនអាចធ្វើឧបាស្រ័យទៅតុលាការថ្នាក់លើបន្ថែមទៀតឡើយ។

**ការលុបចោលនូវការរក្សាការពារ** ត្រូវធ្វើឡើងនៅតុលាការដែលចេញដីកាសម្រេចរក្សាការពារ ដូចគ្នានឹងការតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែរ។ ការលុបចោលនៃការរក្សាការពារ រួមមានការលុបចោលការរក្សាការពារដោយសារការមិនដាក់ពាក្យបណ្ដឹង

---

[17]. មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[18]. មាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[19]. មាត្រា ៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

អង្គសេចក្តី[20], ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព[21] និងការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស[22]។ តុលាការដែលទទួលបានពាក្យសុំលុបចោល ត្រូវវិនិច្ឆ័យអំពីការស្នើសុំលុបចោលដោយផ្អែកលើមូលហេតុនៃការលុបចោលនីមួយៗខាងលើ។ ឧទាហរណ៍ ចំពោះករណីស្នើសុំឱ្យលុបចោលនូវការរក្សាការពារដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍, នៅពេលទទួលបានពាក្យសុំនេះពីកូនបំណុល, តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយបង្គាប់ឱ្យដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីនោះ ដោយកំណត់អំឡុងពេលមិនតិចជាង ២ សប្តាហ៍។ បើម្ចាស់បំណុលមិនបានដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមពេលកំណត់ទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុល។

## ២-ការអនុវត្តជាក់ស្តែងក្នុងការចេញដីកាសម្រេចរក្សាការពារ

នៅក្នុងការអនុវត្តជាក់ស្តែង, ការចេញដីកាសម្រេចរក្សាការពារ ជួបនូវបញ្ហាប្រឈមមួយចំនួន *(ក)* ដែលទាមទារឱ្យមាននូវដំណោះស្រាយទាំងសម្រាប់រយៈពេលចំពោះមុខ ទាំងសម្រាប់រយៈពេលវែង *(ខ)*។

### ក-បញ្ហាប្រឈមក្នុងការអនុវត្តការចេញដីកាសម្រេចរក្សាការពារ

- **ការបែងចែកមិនដាច់រវាងភាពចាំបាច់នៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ៖** មាត្រា ៥៤៥ កំណត់ថា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ *"ក្នុងករណីដែលមានការព្រួយបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ"* ហើយមាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ថា តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន *"ក្នុងករណីដែលមានការព្រួយបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួល*

---

[20]. មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[21]. មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[22]. មាត្រា ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

*ស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ*”។ តើ *“ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ”* និង *“ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ”* មានភាពខុសគ្នាយ៉ាងដូចម្តេច? លើការជាក់ស្តែង យើងមិនអាចធ្វើការបែងចែកឱ្យដាច់ពីគ្នារវាងភាពចាំបាច់ទាំង ២ នេះនោះទេ។ បើផ្អែកតាមមាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងពីគោលគំនិតនៃការចាត់ចែងរក្សាការពារ, ភាពចាំបាច់នៃដីកាសម្រេចទាំង ២ ខាងលើនេះ គួរតែមានភាពដូចគ្នា គឺ *“ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យរបស់កូនបំណុលនៃការអនុវត្ត*”។ ធាតុពិតមូលដ្ឋានតែមួយគត់ដែលអាចឱ្យយើងអាចបែងចែកដាច់ពីគ្នារវាង ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវប្រើនៅពេលដែលសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ គឺ *“សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់”* ហើយដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវប្រើនៅពេលដែលសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ គឺ *“សិទ្ធិលើវត្ថុ”*។

- **ការកំណត់ខ្លឹមសារនៃដីកាសម្រេចចាត់ចែងរក្សាការពារ៖** មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តថា “តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬមិនធ្វើអំពើណាមួយជាកំណត់ ឬឱ្យកូនបំណុលផ្តល់តាវកាលិក ឬឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ឬធ្វើការចាត់ចែងផ្សេងទៀតបាន **តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណង**នៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន”។ ខ្លឹមសារនៃការចាត់ចែងជាបណ្តោះអាសន្ន ត្រូវតែកំណត់ “**ត្រឹមកម្រិតនៃភាពចាំបាច់**” និង “**ដើម្បីសម្រេចគោលបំណង**” នៃពាក្យសុំចេញដីកាសម្រេចនេះ ដែលគោលបំណងនេះ គឺ **“ការរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ[23]”**។ ប៉ុន្តែ លើការជាក់ស្តែង ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នមួយចំនួន បានចេញលើសពីកម្រិតនៃភាពចាំបាច់នេះ និងលើសពីគោលបំណងនៃ **“ការរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ”** ជាអាទិ៍ ការហាមឃាត់មិនឱ្យកូនបំណុលបន្តស្នាក់នៅលើផ្ទះដែលបាននិងកំពុងស្នាក់នៅ

[23]. មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាំងពីមុនពេលមានវិវាទមក ឬហាមមិនឱ្យជួលនូវអចលនវត្ថុដែលកំពុងជួលស្រាប់ ឬការបង្គាប់ឱ្យវាយកម្ទេចចោលនូវរបង ឬការប្រផ្សេងៗដែលមានស្រាប់នៅលើទីតាំងដីវិវាទជាដើម។ ការចេញដីកាសម្រេចបែបនេះ អាចហួសពីភាពចាំបាច់នៃការរក្សាការពារ និងផ្ទុយពីលក្ខណៈនៃការរក្សាការពារ។ ចំពោះវិវាទបែបនេះ ការចេញដីកាសម្រេចរក្សាការពារត្រឹមកម្រិតហាមឃាត់មិនឱ្យកូនបំណុលបន្តសាងសង់របង ឬការប្រផ្សេងៗលើដីវិវាទ ឬមិនឱ្យចាត់ចែងដីវិវាទ គឺធ្លុនល្មមសម្រាប់រក្សាការពារសិទ្ធិរបស់ម្ចាស់បំណុល ដើម្បីរង់ចាំការសម្រេចឱ្យបានដាក់លាក់ក្នុងបណ្ដឹងអង្គសេចក្ដី ហើយការសម្រេចត្រឹមកម្រិតនេះ គឺស្របនឹងចរិតនៃការរក្សាការពារត្រង់លក្ខណៈបន្ទាប់បន្សំពីបណ្ដឹងអង្គសេចក្ដី និងលក្ខណៈបណ្ដោះអាសន្ន។ លើសពីនេះ ការចេញដីកាសម្រេចរក្សាការពារត្រូវតែពិចារណាឱ្យបានល្អិតល្អន់អំពីលទ្ធភាពនៃការធ្វើបដិទាន ជាពិសេសការធ្វើបដិទាននូវការខូចខាតដែលអាចកើតមានឡើងចំពោះកូនបំណុល ពីព្រោះការរក្សាការពារមិនមែនជាការកំណត់ស្ថាពរនៃសិទ្ធិនោះទេ ហើយការសម្រេចនៅក្នុងការរក្សាការពារអាចត្រូវបានផ្លាស់ប្ដូរដោយការសម្រេចនៅក្នុងអង្គសេចក្ដី។

- **ការមិនកំណត់ច្បាស់លាស់ពីប្រភេទដីកាសម្រេចរក្សាការពារ៖** ខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ត្រូវបានសរសេរឡើងទៅតាមទម្រង់ជាច្រើន ហើយក្នុងនោះយើងអាចកត់សម្គាល់ឃើញនូវការសរសេរដែលមានខ្លឹមសារថា ហាមឃាត់មិនឱ្យកូនបំណុលធ្វើការលក់ដូរជួល បញ្ចាំ ធ្វើប្រទានកម្ម ដាក់ហ៊ីប៉ូតែក ឬធ្វើការចាត់ចែងនានាលើវត្ថុណាមួយ ជាអាទិ៍។ តើការសរសេរនូវខ្លឹមសារដីកាសម្រេចរក្សាការពារបែបនេះត្រឹមត្រូវដែរឬទេ? តើការចេញដីកាសម្រេចបែបនេះមានអានុភាពដូចម្ដេច? មានទស្សនៈមួយចំនួនបកស្រាយថា ដីកាសម្រេចនេះអាចជាការរឹបអូសជាបណ្ដោះអាសន្ន ឬជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយសារតែការសរសេរបែបនេះគ្រាន់តែជាការរៀបរាប់លម្អិតអំពីសិទ្ធិដែលត្រូវបានហាមឃាត់ដោយសារការរក្សាការពារប៉ុណ្ណោះ។ ប៉ុន្តែ, ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានគោលបំណងថែរក្សាទ្រព្យសម្បត្តិរបស់កូនបំណុល សម្រាប់ការអនុវត្តដោយបង្ខំដោយប្ដូរជាប្រាក់ ដើម្បីយកទៅសងម្ចាស់បំណុលនាពេលអនាគត។ យើងអាចបកស្រាយថា ការរឹបអូសជាបណ្ដោះអាសន្នមានអានុភាពថែរក្សាតម្លៃសេដ្ឋកិច្ចនៃវត្ថុ ដោយហាមឃាត់មិនឱ្យកូនបំណុលអាចចាត់ចែងបាន ឬមិនអាចចាត់ចែងជាស្ថាពរ។ មានន័យថា នៅពេលមានការរឹបអូសជាបណ្ដោះអាសន្នលើទ្រព្យសម្បត្តិណាមួយរបស់កូនបំណុល នោះកូនបំណុលក្នុងនាមជាកម្មសិទ្ធិករត្រូវបានដកហូតនូវសិទ្ធិចាត់ចែង ប៉ុន្តែ ការរឹបអូសនេះមិនមានអានុភាពហាមឃាត់មិនឱ្យកូនបំណុលប្រើប្រាស់ និងអាស្រ័យផលឡើយ។ ហេតុនេះ ការបកស្រាយថា ជាការរឹបអូសជាបណ្ដោះអាសន្ន

ចំពោះដីកាសម្រេចរក្សាការពារដែលមានខ្លឹមសារហាមឃាត់មិនឱ្យជួលជាអាទិ៍ ពុំទាន់ត្រឹមត្រូវទាំងស្រុងនោះទេ។ ទន្ទឹមនេះ, ការបកស្រាយថាជាការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ក៏មិនទាន់គ្រប់ជ្រុងជ្រោយដែរ ពីព្រោះថា ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ត្រូវមានខ្លឹមសារជាក់លាក់ថាជាការហាមឃាត់ការផ្ទេរការកាន់កាប់ ឬការហាមឃាត់ការចាត់ចែងលើវត្ថុវិវាទ។ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ពុំមានអានុភាពហាមឃាត់មិនឱ្យកូនបំណុលប្រើប្រាស់ និងអាស្រ័យផលលើវត្ថុវិវាទឡើយ លើកលែងតែនៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នបានកំណត់យ៉ាងច្បាស់ថា ដកហូតវត្ថុដែលជាកម្មវត្ថុវិវាទពីកូនបំណុល ហើយប្រគល់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រង ឬអនុញ្ញាតឱ្យម្ចាស់បំណុលប្រើប្រាស់បន្ត[24]។

**- ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី៖** ផ្អែកតាមមាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនេះមានរយៈពេលមិនតិចជា ២ សប្តាហ៍នោះទេ។ ប្រសិនម្ចាស់បំណុលមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី និងឯកសារដែលបញ្ជាក់ពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីនេះទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល។ ក្នុងការអនុវត្ត, មានម្ចាស់បំណុលបានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីនោះទេ។ ម្ចាស់បំណុលមានកាតព្វកិច្ចដាក់ពាក្យបណ្តឹងអង្គសេចក្តី ទាល់តែមានការបង្គាប់ពីតុលាការ តាមពាក្យសុំរបស់កូនបំណុល ដែលនេះជាបន្ទុកសម្រាប់កូនបំណុល ទាំងលើប្រាក់ប្រដាប់ក្តី ទាំងលើភស្តុតាង។ ប៉ុន្តែ ជាសមធម៌ ម្ចាស់បំណុលដែលស្នើសុំដាក់រក្សាការពារគួរតែមានកាតព្វកិច្ចដាក់ពាក្យបណ្តឹងអង្គសេចក្តីក្នុងរយៈពេលមួយកំណត់ ដោយមិនចាំបាច់ទាល់តែមានពាក្យសុំរបស់កូនបំណុលនោះទេ។

**- ការប្រើប្រាស់នូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ក្នុងគោលបំណងសម្រេចនូវការអនុវត្តដោយបង្ខំ ដើម្បីជាមធ្យោបាយឆាប់រហ័សជំនួសឱ្យការធ្វើបណ្តឹងអង្គសេចក្តី** (ផ្លូវកាត់) ក៏ជាបញ្ហាប្រឈមដែលត្រូវបានសង្កេត

---

24. “ជាគោលការណ៍អនុវត្តនៅប្រទេសជប៉ុន គឺអនុញ្ញាតឱ្យកូនបំណុលបន្តប្រើប្រាស់វត្ថុដែលជាកម្មវត្ថុវិវាទ”។ សូមអានឯកសារពន្យល់ “ការរក្សាការពារក្នុងរឿងរដ្ឋប្បវេណី ផ្នែកទី២” ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ MAEDA Yuta, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨, ទំព័រទី២៨។

ឃើញជាញឹកញាប់ផងដែរ។ ដូចបានគូសបញ្ជាក់ពីខាងលើ ដីកាសម្រេចប្រភេទនេះធ្វើឡើងក្នុងគោលបំណងជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងលើម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។

-**ការប្ដឹងសុំរក្សាការពារដដែលៗ៖** ក្រៅបញ្ហាខាងលើ ក៏នៅមានបញ្ហាផ្សេងទៀតផងដែរ ដូចជា បញ្ហានៃការចេញដីកាសម្រេចរក្សាការពារដដែលៗ ដោយមិនមានមូលហេតុថ្មី ឬដោយមិនមានការប្រែប្រួលស្ថានភាពអ្វី ក្រោយពេលដែលដីកាសម្រេចនេះត្រូវបានសម្រេចលុបចោល។ ច្បាប់មិនបានហាមមិនឱ្យមានការប្ដឹងសុំដីកាសម្រេចរក្សាការពារម្ដងហើយម្ដងទៀត ទោះបីជាគ្មានមូលហេតុនៃភាពចាំបាច់ថ្មីក៏ដោយនោះទេ។ បញ្ហាកើតឡើងជាញឹកញាប់ដោយសារតែក្នុងការអនុវត្តជាក់ស្ដែង ភាគច្រើននៃដីកាសម្រេចរក្សាការពារពុំមានបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគនោះទេ។ ករណីនេះជាការរំខានដល់តុលាការផង និងដល់កូនបំណុលផងក្នុងករណីដែលតុលាការថ្មីបានចេញដីកាសម្រេចរក្សាការពារដោយផ្អែកលើមូលហេតុដដែល ប៉ុន្តែដីកាសម្រេចរក្សាការពារនេះត្រូវបានសម្រេចលុបចោលច្រើនដងរួចហើយដោយតុលាការជាន់ខ្ពស់។

### ខ-សេចក្ដីសម្រេចចិត្តរបស់អង្គមហាសន្និបាតវិស័យយុត្តិធម៌ឆ្នាំ ២០២៤

ដោយពិនិត្យឃើញពីបញ្ហាប្រឈមក្នុងការអនុវត្តពាក់ព័ន្ធនឹងការចេញដីកាសម្រេចរក្សាការពារនេះ មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត ដែលត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ និងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ ថ្នាក់ដឹកនាំសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងចៅក្រម និងព្រះរាជអាជ្ញានៅទូទាំងប្រទេស បានលើកចំណុចពាក់ព័ន្ធនឹងការចេញដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវតាមប្រភេទនៃការចាត់ចែងរក្សាការពារ និងមិនទាន់មានសង្គតិភាពលើទម្រង់នៃដីកាសម្រេចរក្សាការពារ ព្រមទាំងពុំមានលក្ខខណ្ឌតាមច្បាប់គ្រប់គ្រាន់ក្នុងការចេញដីកាសម្រេចរក្សាការពារមកធ្វើជាប្រធានបទមួយនៃកិច្ចពិភាក្សា។ ឆ្លងកាត់ការពិភាក្សាយ៉ាងផុសផុល អង្គមហាសន្និបាតបានសម្រេចថា *"រៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទម្រង់រួមនៃដីកាសម្រេចរក្សាការពារ នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីធានាសង្គតិភាព ទាំងលើទម្រង់នៃដីកាទាំងលើខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ តាមប្រភេទនៃការចាត់ចែងរក្សាការពារ និងអាចយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ ក្នុងការអនុវត្តការងារនេះ, អង្គមហាសន្និបាត បាន*

*សម្រេចប្រគល់ភារកិច្ចជូន ក្រសួងយុត្តិធម៌ ដើម្បីរៀបចំឱ្យមានទម្រង់រួមនៃដីកាសម្រេចរក្សាការពារ ដោយមានការពិគ្រោះយោបល់ជាមួយសាលាជម្រះក្តីទាំងអស់មុននឹងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស”។* ជាលទ្ធផល, ក្រុមការងារក្រសួងយុត្តិធម៌កំពុងពិនិត្យមើលទម្រង់ និងខ្លឹមសារនៃដីការក្សាការពារដែលរៀបចំឡើងដោយគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ ក្រោមកិច្ចសហការរបស់អង្គការ JICA និងក្រសួងយុត្តិធម៌ ដើម្បីដាក់ជូនតុលាការទូទាំងប្រទេសប្រើប្រាស់។ ទន្ទឹមនេះ, បញ្ហាប្រឈមខាងលើ និងបញ្ហាប្រឈមផ្សេងទៀត ក៏នឹងក្លាយជាកម្មវត្ថុនៃការធ្វើវិសោធនកម្មនាពេលខាងមុខ ក្នុងក្របខ័ណ្ឌនៃការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ។